# ខ្លឹមសារសង្ខេប

## សេចក្តីសម្រេចលើបញ្ហាបន្ទាន់បន្ទំដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន C22/I/46 ០១ កក្កដា ឆ្នាំ ២០០៨

**ពាក្យគន្លឹះ÷** សមភាពនៃភាគី ជំហរឬនីតិវិធីខុសគ្នា សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី អំណះអំណាងផ្ទាល់មាត់

## ១. អង្គហេតុនិងប្រវត្តិនីតិវិធី

ក្នុងដំណាក់កាលពិចារណាអំពីការឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំលើកអំណះអំណាងផ្ទាល់មាត់ក្នុងរយៈពេលដូចភាគីដទៃ និងបានធ្វើសំណើមកអង្គបុរេជំនុំជម្រះ (PTC)។

## ២. សំអាងហេតុនិងសេចក្តីសម្រេច

PTC បានចេញសេចក្តីម្តងរួចហើយ។ PTC ទទួលស្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណី មានផលប្រយោជន៍ផ្ទាល់ក្នុងរឿងក្តីខុសគ្នាពីព្រះរាជអាជ្ញា។ ពួកគាត់អាចស្នើសុំសំណង វាទាល់តែមានការចាប់ផ្តើមបណ្តឹងព្រហ្មទណ្ឌជាមុន។ នេះជានីតិវិធីពាក់ព័ន្ធឃុំខ្លួន មិនមែនពាក់ព័ន្ធការទារសំណង ក្នុងសវនាការចម្បងទេ។ ដើមបណ្តឹងរដ្ឋប្បវេណី មិនបានលើកអំណះអំណាង ហេតុអ្វីពួកគេត្រូវការពេលច្រើន។

ដើមបណ្តឹងរដ្ឋប្បវេណី ទាមទារនិយាយផ្ទាល់។ PTC បានសម្រេចរួចហើយ ជាទូទៅ ពួកគេមិនអាចនិយាយផ្ទាល់បានទេ គឺអាចធ្វើឡើងតាមរយៈមេធាវី (វិធានទី៧៧.១០ នៃវិធានផ្ទៃក្នុង អវតក)។

PTC បដិសេធនូវសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

## ៣. ខ្លឹមសារដកស្រង់

The PTC finds that no such general principle exists with respect to the length of oral submission. Even if it did, such a principle would simply mean that as far as their position is equal, Civil Parties should be treated in the same way. This is not the case.

ការសម្រេចនេះពាក់ព័ន្ធដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងនីតិវិធីរឿងក្តីព្រហ្មទណ្ឌ។ វាអាចពាក់ព័ន្ធផងដែរដល់គោលការណ៍សមភាពនៃភាគី ក្នុងដំណើរការក្តីព្រហ្មទណ្ឌ។

## ៤. ប្រភពឯកសារ

សម្រាប់ឯកសារទាំងស្រុងអាចរកបាន... f2a74d7b7ed8d3f8617ec7dd4f5d5837.pdf